# ការអនុវត្តន៍ល្អ

## ការស្តុកក្រណាត់

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

គុណភាពរបស់ផលិតផលសំរេចអាស្រ័យលើគុណភាពក្រណាត់ដែលយកមកប្រើប្រាស់ ។ ក្រណាត់ត្រូវរក្សាទុកនៅក្នុងលក្ខណៈល្អ និងដាក់តាមប្រភេទក្រណាត់ ។ ប្រព័ន្ធស្តុកដែលល្អរក្សាក្រណាត់នៅក្នុងបរិយាកាសល្អ នឹងអាចតាមដានពតិមានស្តីពីក្រណាត់ដែលបានប្រើប្រាស់នៅក្នុងផលិតកម្ម ។ សូមមើលសេចក្តីណែនាំការអនុវត្តន៍ល្អស្តីពី ការរៀបចំឃ្លាំង និងការគ្រប់គ្រងស្តុកក្នុងឃ្លាំងសំភារៈជំនួយ ។

### *ការអនុវត្តន៍ល្អស្តីពីការស្តុកក្រណាត់*

កំណត់សំគាល់ និងស្តុកក្រណាត់តាមដុំ ទទឹង បាច់ ស្តាយ ឡូត និងពណ៌ ( រូបភាពទី១ ) ។

ប្រើប្រាស់ប្រព័ន្ធប័ណ្ណសំគាល់ស្តុក ដើម្បីតាមដានតុល្យភាពរបស់ស្តុក ( រូបភាពទី២ ) ។

ដាច់ខាតកុំស្តុកក្រណាត់នៅលើឥដ្ឋ ត្រូវស្តុកក្រណាត់នៅលើធ្នើរ ( រូបភាពទី៣ ) ។

ត្រូវស្តុកក្រណាត់ផ្តេក កុំស្តុកបញ្ឈរ ( រូបភាពទី១ ដល់ទី៣ ) ។

រក្សាកំណត់ត្រានៃដុំក្រណាត់ដែលបានប្រើប្រាស់ហើយនៅក្នុងផលិតកម្ម ធ្វើដូច្នេះអាចអោយគេសំគាល់បញ្ហាគុណភាពបានយ៉ាងងាយស្រួល ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ កាត់បន្ថយចំណាយថ្លៃដើម ព្រោះមិនសូវមានក្រណាត់ខូច
- ✓ ផលិតសំលៀកបំពាក់ចេញពីបាច់ក្រណាត់តែមួយ ដែលអាចធានាបាននូវគុណភាពពណ៌ និងគុណភាពក្រណាត់
- ✓ បង្កើនផលិតភាព តាមរយៈការកាត់បន្ថយពេលវេលាស្វែងរកក្រណាត់
- ✓ ធ្វើអោយការងាររាប់ស្តុកកាន់តែងាយស្រួល

### តាមរបៀបណា:

- ✓ ធានាថាមានធ្នើរគ្រប់គ្រាន់សំរាប់ស្តុកក្រណាត់អោយផុតពីឥដ្ឋ
- ✓ បង្កើតប្រព័ន្ធប័ណ្ណសំគាល់ស្តុក ដើម្បីសំគាល់ក្រណាត់តាមដុំ ទទឹង បាច់ ស្តាយ ឡូត និងពណ៌
- ✓ បង្កើតប្រព័ន្ធតាមដានក្រណាត់ប្រើប្រាស់នៅក្នុងផលិតកម្ម
- ✓ ធានាថាប្រធាន និងបុគ្គលិកឃ្លាំងរោងចក្រទទួលខុសត្រូវលើការស្តុក ចែកចាយ និងតាមដានការប្រើប្រាស់ក្រណាត់

### តំលៃ:

$ ______

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់

អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉ែល betterfactories@ilo.org